ស្របទៅតាមខ្ជង់ នៅក្នុងពាក្យនេះ។ ប្រសិនបើចំនួនណាមួយ <u>ពីខែមុន</u> មានតិច ឬ ច្រើនជាងធម្មតានោះ សូមសរសេរចំនួនប្រាក់ចំណូល តាមធម្មតារបស់បុគ្គលនោះ។

(គ) ប្រសិនបើមានអ្នកណាម្នាក់ ធ្វើការឱយខ្លួនឯងនោះ សូមសរសេរប្រាក់ចំណូលរបស់អ្នកនោះ ពីការងាររបស់ខ្លួនឯង ឧទាហរណ៍ ប្រាក់ចំណូលបានមកពីការថែទាំកូនក្មេងនៅក្នុងផ្ទះ ឬ ការធ្វើស្រែចំការ ជាដើមនោះ។ សូមទូរសព្ទ័ទៅលេខ នៅខាងលើបំផុតនៃទំព័រនេះ ប្រសិនបើលោកអ្នកត្រូវការឱយគេជួយនោះ។

(ឃ) ប្រសិនបើលោកអ្នក ជាអ្នកផ្តល់ការថែទាំកូនក្មេងតាមផ្ទះ ដាក់ពាក្យសុំផលកម្រៃកំរិតទី១នោះ(Tier I) សូមផ្ទាប់នូវឯកសារ ប្រាក់ចំណូល បញ្ជាក់ទ្រទ្រង់ថានេះរបស់លោកអ្នកផង។

(ង) សូមចុះហត្ថលេខាលើសំណុំពាក្យ ហើយ បំពេញលេខ SOCIAL SECURITY របស់លោកអ្នក នៅក្នុងលេខ #៥ ផង។ ប្រសិនបើលោកអ្នកគ្មានលេខនេះទេ សូមសរសេរថា "NONE"។

==========

៥. ហត្ថលេខា និង លេខ SOCIAL SECURITY:

(ក) ពាក្យនេះចាំបាច់ត្រូវតែមានហត្ថលេខា របស់សមាជិកគ្រួសារម្នាក់ដែលជាមនុស្សធំពេញវ័យ។

(ខ) សមាជិកគ្រួសារម្នាក់ដែលជាមនុស្សធំពេញវ័យ ដែលចុះហត្ថលេខាលើពាក្យនេះ ចាំបាច់ត្រូវតែបំពេញលេខ SOCIAL SECURITY របស់ខ្លួន។ ប្រសិនបើសាមីខ្លួន គ្មានលេខនេះទេនោះ សូមសរសេរថា "NONE" ប្រែថាគ្មាន។ លេខ SOCIAL SECURITY ជាការមិនចាំបាច់ទេ ប្រសិនលោកអ្នកមានចុះលេខប្រាក់ FOOD STAMP លេខប្រាក់ជំនួយបណ្តោះអាសន្នន៍សម្រាប់គ្រួសារខ្វះខាត(TANF) ឬ លេខករណីយ ជំនួយដល់គ្រួសាររស់នៅកន្លែងជនជាតិ INDIAN (FDPIR) នោះ ឬ ប្រសិនលោកអ្នកដាក់ពាក្យសុំឱយកូនចិញ្ចឹមម្នាក់នោះ។

(គ) ប្រសិនបើលោកអ្នកដាក់ពាក្យសុំផលកម្រៃ ក្នុងថានេះជាអ្នកផ្តល់ការថែទាំកូនក្មេងតាមផ្ទះនោះ(Tier I) សូមបញ្ជាក់ឱយដឹងអំពីរឿងនេះ នៅក្នុងផ្នែកនៃពាក្យនេះផង។

==========